# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមករា ឆ្នាំ២០១៥
## និងទិសដៅការងារ ខែកុម្ភៈ ឆ្នាំ២០១៥

( ពីថ្ងៃទី២៦/១២/២០១៤ ដល់ ២៥/០១/២០១៥ )

ក្នុងគោលដៅចូលរួមចំណែកអនុវត្ត ”គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព”របស់រាជរដ្ឋាភិបាល ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែធ្នូ ឆ្នាំ២០១៤ កន្លងទៅ សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

នៅក្នុងខែមករាឆ្នាំ២០១៥នេះ មានការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានប្រតិបត្តិការដោយ មន្ទីរប្រឆាំងគ្រឿងញៀន និងបណ្តាស្នងការដ្ឋាននគរបាល ក៏ដូចជាបញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី-ខេត្ត ចំនួន ២៣ គឺ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ចាម, កំពង់ឆ្នាំង, សៀមរាប, កំពង់ធំ, បាត់ដំបង, បន្ទាយ មានជ័យ, ស្ទឹងត្រែង, ស្វាយរៀង, ក្រចេះ, ពោធិ៍សាត់, កំពត, កោះកុង, មណ្ឌលគិរី, ព្រះវិហារ, ឧត្តរមានជ័យ, ប៉ៃលិន, រតនគិរី និង ខេត្តត្បូងឃ្មុំ ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបដោយសមត្ថកិច្ចអនុវត្តន៍ច្បាប់ខាងលើ មានបទល្មើសគ្រឿងញៀន១ករណីធំ ដែលបង្ក្រាបដោយកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន ព្រមទាំងចាប់យកគ្រឿងញៀនសំយោគប្រភេទមេតំហ្វេតាមីនក្រាមម្សៅ ៨០២,៤៤ ក្រាម និង ម្សៅសង្ស័យគ្រឿងញៀន ៨.៥១២,៤១ ក្រាម ។

## II. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំលើការងារជាគោលសំខាន់ៗ មានជាអាទិ៍ ៖

- បន្តជំរុញក្រសួងអប់រំ យុវជន និងកីឡា លើការងាររៀបចំសាលារៀនបៃតង ( សាលារៀនគ្មានគ្រឿងញៀន ),

ការងារប្រឡងប្រជែងតែងកំណាព្យដែលមានខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការផលិតឯកសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន

- ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅខេត្តបន្ទាយមានជ័យ សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការ UNODC ដើម្បីធ្វើការបូកសរុបលទ្ធផលនៃការកៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- ជំរុញការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញឱ្យបានឆាប់រហ័ស
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួងសុខាភិបាល សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀត ពីកម្មវិធីម្ជុល/ស៊ីរ៉ាំង និងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងសេវាព្យាបាលរបស់អង្គការមិត្តសំឡាញ់
- បន្តជំរុញការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាអ្នកញៀនគ្រឿងញៀននៅក្នុងពន្ធនាគារ
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការ និងតុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ចុះទៅពិភាក្សាលើការងារប្រមូលទិន្នន័យព័ត៌មានពាក់ព័ន្ធនឹងការងារព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នរបស់ឯកជន សម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទា
- សហការជាមួយស្ថាប័នអនុវត្តន៍ច្បាប់ ធ្វើសម្រង់ទិន្នន័យបទល្មើសនានាក្នុងឆ្នាំ២០១៤ ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន និងបទល្មើសគ្រឿងញៀនដោយបញ្ជាក់ពីមុខរបរឱ្យបានច្បាស់លាស់
- បន្តជំរុញការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ជាមួយក្រសួងយុត្តិធម៌
- បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តតាមដានការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

នៅក្នុងខែមករាឆ្នាំ២០១៥នេះ ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារដែលបានដាក់ចេញកាលពីខែធ្នូឆ្នាំ២០១៤ កន្លងទៅ ក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត នៅតែបន្តអនុវត្តកម្មវិធីអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមរយៈ ស្ថានីយវិទ្យុជាតិ វិទ្យុរាជធានី ខេត្ត តាមកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

ដោយឡែក ការអប់រំពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ ក្រៅពីការចូលរួមដោយក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក៏មានការចូលរួមអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ ដោយគណៈកម្មា-ធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៦ គឺ ខេត្តព្រះសីហនុ, ស្វាយរៀង, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, និង ខេត្តក្រចេះ ។ លទ្ធផលជារួម មានមហាជនចូលរួមប្រមាណ **២១៣.១០៨** នាក់ លើ **៦៣.២០៦** នាក់ នៃខែធ្នូ ឆ្នាំ ២០១៤ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១) ។

ក្នុងចំណោមសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តនូវការងារមួយចំនួនដូចខាងក្រោម ៖

- ផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីផ្សាយផ្ទាល់របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នៅថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៥ តាមកម្មវិធី និងប្រធានបទដូចខាងក្រោម ៖
  - កម្មវិធីសុវត្ថិភាពអ្នក ក្រោមប្រធានបទ តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យយុវជនចៀសផុតពីគ្រឿងញៀន
  - កម្មវិធីចក្ខុវិស័យកម្ពុជា ក្រោមប្រធានបទ ការអនុវត្តច្បាប់និងការបង្ការការជួញដូរ និងការប្រើបំពានគ្រឿងញៀននៅកម្ពុជា
  - កម្មវិធីសភាអ៊ីនធឺណែតក្រោមប្រធានបទ ផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងដំណោះស្រាយ
- សហការរៀបចំពិធីប្រកាសលទ្ធផលនិងផ្តល់រង្វាន់ជ័យលាភី ដល់សិស្សពូកែគូរគំនូរប្រឆាំងគ្រឿងញៀនក្នុងចំណោមសិស្សានុសិស្សនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ ក្នុងខេត្តកោះកុង កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម អនុប្រធាន អ.ជ.ប.គ.ញ (អ្នកចូលរួម ៨៥៥ នាក់)
- សម្របសម្រួល ណែនាំដល់រាជធានី និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តគោលដៅ ដែលមានតំបន់ទេសចរណ៍ ដើម្បីជំរុញការផ្សព្វផ្សាយអប់រំ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន នៅក្នុងឱកាសបុណ្យឆ្លងឆ្នាំសកល (២០១៤-២០១៥)
- សហការជាមួយអគ្គនាយកដ្ឋានវិទ្យុ ទូរទស្សន៍បាយ័ន, ទូរទស្សន៍ហង្សមាស, ម៉ាយធីវី បញ្ច្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈកម្មវិធីប្រគំតន្ត្រីស្រុកស្រែ, កម្មវិធីតន្ត្រីទេសចរណ៍ខាវ៉ាបារ, តន្ត្រីកូកាកូឡា, តន្ត្រីឆ្លងឆ្នាំសកល (២០១៤-២០១៥) នៅខេត្តកំពង់ស្ពឺ, សៀមរាប, បន្ទាយមានជ័យ, បាត់ដំបង និងខេត្តព្រះសីហនុ មានមហាជនចូលរួមប្រមាណ ១៨៧.៧០០ នាក់ ។
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុង**ខែមករា ឆ្នាំ**

២០១៥ មានអ្នកអានចំនួន **២៤.០៣៥** ដង លើ **២៥.៣៤២** ដង នៃធ្នូ ឆ្នាំ២០១៤ ។

## ២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមសម្របសម្រួលកិច្ចប្រជុំផ្សព្វផ្សាយការសិក្សាស្រាវជ្រាវស្តីពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀននៅកម្ពុជា (CIPI) ដែលរៀបចំដោយអង្គការ FHI360 នៅខេត្តកណ្តាល (ថ្ងៃទី៣០/០១/២០១៥) ដើម្បីបង្កើនការយល់ដឹងពីការសិក្សាស្រាវជ្រាវស្តីពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍និងគ្រឿងញៀននៅកម្ពុជា ក្នុងចំណោមមន្ត្រីធ្វើការតាមសេវាកម្សាន្ត ដល់អ្នកពាក់ព័ន្ធទាំងអស់ក្នុងតំបន់គោលដៅ (អ្នកចូលរួម ៦០ នាក់) ។

### ២.២. ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

- ចុះទៅពិភាក្សាលើការងារប្រមូលទិន្នន័យព័ត៌មានពាក់ព័ន្ធនឹងការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នរបស់ឯកជន សម្រាប់អប់រំ បន្សាប ព្យាបាលនិងស្តារនីតិសម្បទា ចំនួន ៣ កន្លែងគឺ មណ្ឌលអប់រំព្យាបាលជនប្រើប្រាស់គ្រឿងញៀននិងបណ្តុះបណ្តាល ចំណេះដឹង, មណ្ឌលអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈពន្លឺថ្មី និង មណ្ឌលសង្គ្រោះជនរងគ្រោះដោយសារគ្រឿងញៀនកម្ពុជា កាលពីថ្ងៃទី២៣/០១/២០១៥
- ចាត់មន្ត្រី និងសម្របសម្រួលជូនមន្ត្រីរបស់ក្រសួងជាសមាជិកដែលពាក់ព័ន្ធ ទៅធ្វើទស្សនកិច្ចសិក្សាស្វែងយល់លើការងារព្យាបាលដោយផ្អែកលើសហគមន៍ នៅប្រទេសថៃកាលពីថ្ងៃទី១៣-១៦ខែមករា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៣ នាក់, មន្ត្រីស្ថាប័នពាក់ ព័ន្ធ ១៩ នាក់) ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

- រៀបចំកិច្ចប្រជុំពិនិត្យ ពិភាក្សាលើការរៀបចំសមាសភាពការិយាល័យទំនាក់ទំនងព្រំដែន (BLO) ទាំង ១៤ កន្លែង នៅក្នុង ១១ ខេត្ត គឺ ខេត្តកោះកុង ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ (២កន្លែង) ព្រះវិហារ ស្ទឹងត្រែង (២ កន្លែង) តាកែវ កណ្តាល (២ កន្លែង) ត្បូងឃ្មុំ និង ខេត្តស្វាយរៀង ដើម្បីជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៃខេត្តខាងលើ ក្នុងការរៀបចំសមាសភាពនិងទីតាំងរបស់ការិយាល័យ នេះ ឱ្យបានច្បាស់លាស់
- រៀបចំលិខិតស្នើសុំទៅក្រសួងមហាផ្ទៃ ដើម្បីបន្ថែមមន្ត្រីនគរបាលនៅប៉ុស្តិ៍រដ្ឋបាលតាមបណ្តាអធិការដ្ឋាននគរបាលខណ្ឌ ចំណុះស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុបរួម **២៣៨ ករណី** លើ ១៩៧ ករណី នៃខែធ្នូ ឆ្នាំ២០១៤
- ជនសង្ស័យ ឃាត់ខ្លួន សរុបរួម **៤៧៩ នាក់** លើ ៤១៦ នាក់ (ស្រី ៥៧ នាក់) នៃខែធ្នូ ឆ្នាំ២០១៤

ក្នុងចំនួនបទល្មើសគ្រឿងញៀន **២៣៨ ករណី** និងជនសង្ស័យទាំង **៤៧៩ នាក់** ខាងលើគឺ **:**

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចនគរបាលជាតិ **១៩៨ ករណី**, ជនសង្ស័យ **៣៧៥ នាក់** (ស្រី ៣៩ នាក់)
- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចកងរាជអាវុធហត្ថ **៥០ ករណី**, ជនសង្ស័យ **១០៤ នាក់** (ស្រី ១៨ នាក់)

ក្នុងចំនួនជនសង្ស័យ ដែលបានឃាត់ខ្លួនទាំង ៤៧៩ នាក់ ខាងលើ មាន ០៤ សញ្ជាតិ គឺ ខ្មែរ ៤៦៦ នាក់ (ស្រី ៥៦ នាក់), វៀតណាម ៤ នាក់ (ស្រី ០១ នាក់), នីហ្សេរីយ៉ា ០៨ នាក់ (ប្រុស), អង់គ្លេស ០១ (ប្រុស) ត្រូវបានកសាងសំណុំ រឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** មេតំហ្វេតាមីន WY ៤២៥,៧៧ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ ICE ១.៦៩៨,២៨ ក្រាម, ហេរ៉ូអ៊ីន ០,៧៣ ក្រាម, កេតាមីន ៦.២១, ដើមក្រៀម ៣០០៨ ដើម, កញ្ឆាក្រៀម ៤.០០០ ក្រាម និង ម្សៅសង្ស័យគ្រឿងញៀន ៨.៥១២,៤១ ក្រាម
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** ដែលបានចាប់យករួមមាន ម៉ូតូ ១០៧ គ្រឿង, រថយន្ត ៣ គ្រឿង, ប្រាក់កម្ពុជា ៩.២៩២.២០០ រៀល, ប្រាក់វៀតណាម ១.០០០ ដុង, ប្រាក់ថៃ ២.៩០០ បាត, ប្រាក់អាមេរិក ៥២១ ដុល្លារ និង ប្រាក់ចិន ១.០០០ យ័ន (**ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២**)
- ជនសង្ស័យចាប់តាមដីកា មាន ១០ ដីកា = មនុស្ស ១០ នាក់ (ប្រុស) ជនជាតិខ្មែរ
- ការធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ក្នុងខែមករា ឆ្នាំ២០១៥ សរុបចំនួន ៩៧ សំណាក = ៨៧ ករណី ក្នុងនោះ ៖
  - **សំណាកវិជ្ជមានសារធាតុញៀន មាន ៩២ សំណាក = ៨៥ ករណី = ៩៤,៥៩ % គឺ :**
    - ✓ មេតំហ្វេតាមីន ICE ៧៣ សំណាក = ៧៥,២៥ %
    - ✓ មេតំហ្វេតាមីន WY ១៦ សំណាក = ១៦,៤៩ %
    - ✓ កញ្ឆា ០១ សំណាក = ១,០៣ %
    - ✓ កេតាមីន ០២ សំណាក = ២,០៦ %
  - **សំណាកអវិជ្ជមានសារធាតុញៀន ០៥ សំណាក = ២ ករណី = ០៥,១៥ %**

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុងខែមករា ឆ្នាំ២០១៥ នេះ មានដូចតទៅ ៖
  - វត្ថុធាតុដើមចម្រុះ ដែលពាក់ព័ន្ធនឹងតារាងទី**IV** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សរុបចំនួន **៧៩២.៥០០** គ.ក្រ **៦០០** លីត្រ ក្នុងនោះ ៖
    - ✓ វត្ថុធាតុដើមដែលចេញអាជ្ញាបណ្ណដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម មាន ៧០១.០០០គ.ក្រ
    - ✓ វត្ថុធាតុដើម ដែលចេញអាជ្ញាបណ្ណដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ៩១.៥០០ គ.ក្រ ៦០០ លីត្រ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)
- បន្តកិច្ចសហការជាមួយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពាក់ព័ន្ធនឹងនីតិវិធីក្នុងការប្រគល់ជូនក្រសួង

ឧស្សាហកម្មនិងសិប្បកម្ម ដើម្បីគ្រប់គ្រងបន្តនិងចាត់ចែងតាមសមត្ថកិច្ចនូវសារធាតុគីមី ចំនួន ១៤ មុខ ទម្ងន់ ១៨ តោន ៩០០ គីឡូក្រាម
- សហការជាមួយអង្គការ UNODC ដើម្បីរៀបចំបញ្ជូនសំណាកម្សៅរល្វិរមៀតទៅធ្វើការវិភាគឱ្យបានច្បាស់លាស់ថានៅក្នុងម្សៅនោះ មានផ្ទុកនូវសារធាតុអ្វីខ្លះ
- បន្តរៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធការចរាចរ ការរើបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- បាននិងកំពុងបន្តការយកចិត្តទុកដាក់ជំរុញការរៀបចំកិច្ចប្រជុំទ្វេភាគីថ្នាក់ខេត្ត ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ឡាវ ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ឱ្យ បានទៀងទាត់
- ពិនិត្យនិងរៀបចំកសាងផែនការសកម្មភាព ដែលគាំទ្រដល់លិខិតនៃកិច្ចព្រមព្រៀង (LOA) រវាងកម្ពុជា ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនតាមតំបន់ព្រំដែន កម្ពុជា ថៃ នៅឆ្នាំ ២០១៥
- សម្របសម្រួលក្នុងការរៀបចំដំណើរទស្សនកិច្ច ជូនគណៈប្រតិភូជាន់ខ្ពស់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- ពិនិត្យលើឯកសារ ស្តីពីការសម្រេចបានអាស៊ានគ្មានគ្រឿងញៀន ឆ្នាំ២០១៥ ការពិនិត្យឡើងវិញ និងអនុសាសន៍សម្រាប់ឆ្នាំ២០១៥ របស់លេខាធិការដ្ឋានអាស៊ាន
- សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចាត់បញ្ជូនមន្ត្រីសម្របសម្រួលថ្នាក់ជាតិ ទៅចូលរួមប្រជុំត្រៀមរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសហត្ថលេខីក្នុងមហាអនុតំបន់ទន្លេមេគង្គ (MOU) កាលពីថ្ងៃទី១៥-១៦ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងហាណូយ ប្រទេសវៀតណាម (មន្ត្រី អគ្គលេខាធិការដ្ឋាន ០១ នាក់)
- សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចូលរួមសិក្ខាសាលាមហាអនុតំបន់ទន្លេមេគង្គឆ្នាំ ២០១៥ ដើម្បីអភិវឌ្ឍន៍នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ពហុកិច្ចប្រតិបត្តិការ កាលពីថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងប៉េកាំង ប្រទេសចិន (សមាសភាព អគ្គលេខាធិការដ្ឋាន ០២ នាក់, មហាផ្ទៃ ០១ នាក់)
- សម្របសម្រួលជាមួយអង្គការ **UNODC** ដើម្បីចូលរួមសិក្ខាសាលាមហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ ២០១៥ ដើម្បីអភិវឌ្ឍន៍នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ប្រកពព័ត៌មានគ្រឿងញៀនក្នុងតំបន់ កាលពីថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងប៉េកាំង ប្រទេសចិន (អគ្គលេខាធិការដ្ឋាន០២នាក់) ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- រៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងសមាជិក អ.ជ.ប.គ.ញ ដើម្បីពិនិត្យសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ (ថ្ងៃទី២៩ ខែ

មករា ឆ្នាំ២០១៥)

- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បាននិងកំពុងបន្តការពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការ ទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បានកនិងកំពុងបន្តការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តពាក់ព័ន្ធ ដើម្បីធ្វើការកែសម្រួលសមាសភាពរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។
- ក្រសួងមហាផ្ទៃ បានចុះហត្ថលេខាលើផែនការសហប្រតិបត្តិការ ឆ្នាំ២០១៥ ជាមួយក្រសួងនគរបាលនៃ សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានខ្លឹមសារក្នុង**ទំព័រ៣ ចំណុច៣** ពាក់ព័ន្ធនឹងកំណត់ហេតុប្រជុំទ្វេភាគី កម្ពុជា-វៀតណាម លើកទី១៣ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន សារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីផ្សំ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ នៅខេត្តសៀមរាប
- គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បានរៀបចំកិច្ចប្រជុំដើម្បីបូកសរុបលទ្ធផលការងាររបស់គណៈ កម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ឆ្នាំ២០១៤ ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១៥

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- រៀបចំចាត់ចែង សម្របសម្រួលនិងអញ្ជើញវាគ្មិនជាតំណាងមកពីក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធី សភាអ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥
- បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យ ឯកជនដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន
- បន្តជំរុញក្រសួងអប់រំ យុវជន និងកីឡា លើការងាររៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿង ញៀន), ការងារប្រឡងប្រជែងតែងកំណាព្យដែលមានខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការផលិតឯកសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស
- បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមប្រព័ន្ធផ្សព្វ

ផ្សាយនានា

- បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលអប់រំពីបញ្ហាគ្រឿងញៀននៅតាមក្រសួង-ស្ថាប័ន រោង ចក្រ សហគ្រាស និង នៅតាមសហគមន៍
- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តគោលដៅ និងវិស័យឯកជន ដើម្បីបន្ត ការបញ្ជ្រាបការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការប្រគំតន្រ្តីផ្សព្វផ្សាយ ពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជន

## ២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពី គ្រឿងញៀន

- ជំរុញសកម្មភាពចែកចាយឯកសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ឱ្យកាន់តែសកម្ម ថែមទៀតនៅតំបន់គោលដៅសំខាន់ៗ ដើម្បីឱ្យអ្នករងគ្រោះអាចទៅទទួលយកសេវាព្យាបាល នៅមន្ទីរពេទ្យ បង្អែក ឬ មណ្ឌលសុខភាព ដែលនៅជិត
- ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍នៅខេត្តបន្ទាយមានជ័យ សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការ UNODC ដើម្បីធ្វើការបូកសរុបលទ្ធផល នៃការ កៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើ សហគមន៍
- បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការពង្រឹង យន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិ សម្បទាអ្នកញៀនគ្រឿងញៀន
- បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញការរៀបចំកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ ឱ្យបាន ឆាប់រហ័ស
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួងសុខាភិបាល សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿង ញៀនរាជធានីភ្នំពេញ ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀត ពីកម្មវិធីម្ជុល/ស៊ីរ៉ាំង និងការផ្តល់ សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងសេវាព្យាបាលរបស់ អង្គការមិត្តសំឡាញ់
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់ អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាម មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

- បន្តចូលរួមសហការជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ នៅតាមយោធភូមិភាគ និងវរការពារព្រំដែន

- បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ
- ត្រៀមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់ច្រកអាកាសយានដ្ឋានអន្តរជាតិ
- ចូលរួមសន្និសីទស្តីពីការអនុវត្តច្បាប់គ្រឿងញៀននៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងតូក្យូ ប្រទេសជប៉ុន នាថ្ងៃទី២៤-២៦ ខែកុម្ភៈ ឆ្នាំ២០១៥
- ត្រៀមចូលរួមសិក្ខាសាលាអនុតំបន់ ស្តីពីការអភិវឌ្ឍនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ប្រភពព័ត៌មានគ្រឿងញៀនក្នុងតំបន់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ២៧-២៨ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងប៉េកាំង ប្រទេសចិន
- សហការ និងជំរុញមន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល បំប៉នជំនាញស្តីពីការស្រាវជ្រាវ ស៊ើបអង្កេត និងការកសាងឯកសារសំណុំរឿង
- នីតិវិធីក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដល់មន្ត្រីនគរបាល ដែលមានភារកិច្ចពាក់ព័ន្ធ នៅតាមបណ្តាខេត្តគោលដៅ
- សហការជាមួយស្ថាប័នអនុវត្តន៍ច្បាប់ ធ្វើសម្រង់ទិន្នន័យបទល្មើសនានាក្នុងឆ្នាំ២០១៤ ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន និងបទល្មើសគ្រឿងញៀនដោយបញ្ជាក់ពីមុខរបរឱ្យបានច្បាស់លាស់
- បន្តជំរុញការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ជាមួយក្រសួងយុត្តិធម៌
- បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រនៅនឹងកន្លែង (អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ) និងការបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រចល័ត (E-Learning)
- ចុះពង្រឹងតាមដានការអនុវត្តច្បាប់ និងការអនុវត្តសាលក្រមតុលាការ របស់មន្ត្រីអនុវត្តន៍ច្បាប់នៅតាម រាជធានីខេត្តគោលដៅ ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- ចូលរួមសិក្ខាសាលាវេទិកាតំបន់អាស៊ានស្តីពីសារធាតុគីមីផ្សំគ្រឿងញៀ នាថ្ងៃទី១១-១៣ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់
- បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរើបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- សម្របសម្រួលជាមួយប្រទេសថៃ ឡាវ វៀតណាម ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងថ្នាក់ខេត្តនិងខេត្ត ស្រុកនិងស្រុកជាប់ព្រំដែនកម្ពុជា-ថៃ / កម្ពុជា-ឡាវ / កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដោយមានការចូលរួមពីផ្នែកកងទ័ព

- ពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ / កម្ពុជា-ឡាវ និង កម្ពុជា-វៀតណាម
- សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន ប្រទេសវៀតណាម និងប្រទេសឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសឡាវ និងប្រទេសវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- សម្របសម្រួលជូនមន្ត្រីក្រសួងសមាជិកដែលពាក់ព័ន្ធចំនួន ០៣ នាក់ (ក្រសួងមហាផ្ទៃ ០១ នាក់, អគ្គ-នាយកដ្ឋានគយនិងរដ្ឋាករ ០១ នាក់ និងខេត្តបន្ទាយមានជ័យ ០១ នាក់) ទៅចូលរួមវគ្គបណ្តុះបណ្តាលអនុវត្តច្បាប់អាស៊ាន + ៣ លើកទី២ ស្តីពីការប្រឆាំងថ្នាំញៀន ATS និងសារជាតុញៀនផ្សេងទៀត
- សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចូលរួម ៖
  - ✓ កិច្ចប្រជុំក្រុមការងារស្តីពីការត្រួតពិនិត្យ ស៊ើបអង្កេតរួមគ្នានៅតាមកំពង់ផែ និងគោលដៅស៊ើបអង្កេតលើការត្រួតពិនិត្យសារជាតុញៀនប្រភេទថ្មី ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៩-៣០ ខែមករា ឆ្នាំ២០១៥ នៅប្រទេសចិន
  - ✓ ពិធីបើកកិច្ចប្រជុំ Joint Force ស្តីពីកិច្ចប្រតិបត្តិការប្រឆាំងឧក្រិដ្ឋកម្មគ្រឿងញៀនឆ្លងដែន ដែលនឹងប្រព្រឹត្តទៅនៅប្រទេសចិន
  - ✓ កិច្ចប្រជុំវាយតម្លៃ ស្តីពីការអនុវត្តគោលការណ៍អាស៊ានគ្មានគ្រឿងញៀនឆ្នាំ២០១៥ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី ០៥-០៦ ខែកុម្ភៈ ឆ្នាំ២០១៥
  - ✓ ពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់កម្មវិធីបណ្តុះបណ្តាលចល័តស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន (២៥.០២.២០១៥)
  - ✓ សន្និសីទស្តីពីការអនុវត្តច្បាប់គ្រឿងញៀននៅតំបន់អាស៊ី ប៉ាស៊ីហ្វិក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងតូក្យូ ប្រទេសជប៉ុន នាថ្ងៃទី២៤-២៦ ខែកុម្ភៈ ឆ្នាំ២០១៥
  - ✓ ពិធីប្រគល់-ទទួល រថយន្ត សម្ភារៈ បរិក្ខារ សម្រាប់ការិយាល័យ ទំនាក់ទំនងព្រំដែន (BLO) ពីគម្រោង PATROL របស់អង្គការ UNODC
- សម្របសម្រួលរៀបចំដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- រៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ត្រៀមរៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤ និងទិសដៅការងារ ឆ្នាំ២០១៥
- បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ជំរុញការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្រ្តព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយនិងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តជំរុញការរៀបចំយន្តការគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ពីថ្នាក់រាជធានីរហូតដល់ខណ្ឌ សង្កាត់ដើម្បីចូលរួមចំណែកក្នុងការគាំទ្រកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហ-គមន៍ ដោយធ្វើសកម្មភាពនៅតំបន់គោលដៅសំខាន់ៗ
- ជំរុញការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាគ្រឿងញៀននៅក្នុងពន្ធនាគារ
- រៀបចំកម្មវិធីផ្សព្វផ្សាយអំពី អនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ដល់មន្រ្តីរាជការនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍ រដ្ឋបាល មន្រ្តីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្រ្តី ប្រធាន អ.ជ.ប.គ.៣

"ដើម្បីជូនជ្រាប"

- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្រ្តី

"ដើម្បីមុខការ"

- ឯកសារ